សកម្មភាព ៖ តន្ត្រីរាំអង្គុយ

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**សិក្សាសង្គម**

ចម្រៀង និងតន្ត្រី (ចំណេះដឹងបច្ចេកទេស ចលនា ការច្នៃប្រឌិត និងបទពិសោធផ្នែកតន្ត្រី)។

**គោលបំណង**

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(សិក្សាសង្គម)** ប្រាប់បានពីអត្ថន័យ និងបទចម្រៀងមួយចំនួន និងរបៀបធ្វើកាយវិការ។

ច្រៀងចម្រៀង និងធ្វើកាយវិការត្រូវតាមខ្លឹមសារបទចម្រៀង។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកពូកែអី?"។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ បទចម្រៀងដែលអ្នកបានជ្រើសរើស។

**ការរៀបចំ** ៖ ជ្រើសរើសបទចម្រៀងដែលអ្នកចង់ចាក់ ឬ ច្រៀងក្នុងការលេងល្បែងមួយនេះ ។

-ប្រាប់ពីចំណងជើង អត្ថន័យបទចម្រៀងនិងរបៀបធ្វើកាយវិការ ដែលត្រូវលេង។

**សេចក្តីណែនាំ៖**

1. និយាយ៖ ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែងតន្ត្រីរាំអង្គុយជាកូនៗទាំងអស់គ្នា។
2. ចូរឱ្យក្មេងៗទាំងអស់ក្រោកឈរនៅកន្លែងដែលមានទីធ្លាធំទូលាយជៀសវាងកុំឱ្យក្មេងៗធ្វើកាយវិការ ឬ សកម្មភាពប៉ះគ្នា។
3. ចូរប្រាប់ក្មេងៗឱ្យក្រោកឈរទាំងអស់គ្នាបន្ទាប់មកសួរក្មេងៗឱ្យសាកស្រមៃធ្វើខ្លួនដូចជាផ្លែដូចដែលកំពុងយោងទៅយោងមកនៅលើដើម។
4. ប្រាប់ពួកគេពីសេចក្តីណែនាំដូចខាងក្រោម៖
    - ខណៈពេលដែលបទចម្រៀងកំពុងចាក់ ឱ្យក្មេងៗទាំងអស់រាំធ្វើដូចជាផ្លែដូងកំពុងយោលទៅវិញទៅមកទៅតាមខ្យល់។ ត្រូវប្រយ័ត្នកុំឱ្យប៉ះគ្នានឹងមិត្តផ្សេងទៀត។

- នៅពេលដែលបទចម្រៀងបញ្ឈប់ ត្រូវឱ្យពួកគេអង្គុយចុះភ្លាមៗដូចជាផ្លែដូងធ្លាក់ចុះអញ្ចឹង។
- ល្បែងនេះអាចលេងបានយ៉ាងសប្បាយ តែមិនអាចធ្វើឱ្យមានសម្លេងហ៊ោខ្លាំងពេកនោះទេ ព្រោះធ្វើឱ្យស្តាប់សម្លេងបទចម្រៀងមិនសូវលឺច្បាស់។




5. ចាប់ផ្តើមលេងល្បែងមួយនេះ នឹងត្រូវរំលឹកក្មេងៗឱ្យរាំកុំឱ្យភ្លេចឱ្យសោះ។
6. បន្ទាប់ពីលេងល្បែងនេះមួយសន្ទុះក្រោយមក អ្នកត្រូវបញ្ឈប់បទចម្រៀងហើយក្មេងៗទាំងអស់អង្គុយចុះ។
7. នៅពេលដែលក្មេងៗទាំងអស់កំពុងអង្គុយនោះ ប្រាប់ឱ្យក្មេងៗទាំងអស់ក្រោកឈរម្តងទៀត ហើយចាក់បទចម្រៀងម្តងទៀត និងចាប់ផ្តើមលេងវាម្តងទៀត។
8. ធ្វើដដែលៗទៅតាមអ្វីដែលអ្នកត្រូវការ និងមានពេលវេលា។

**ការប្រែប្រួល៖**

សុំឱ្យក្មេងៗទាំងអស់ធ្វើអ្វីផ្សេងៗទៀតក្នុងពេលដែលបទចម្រៀងកំពុងចាក់។ ពួកគេអាចសម្តែងជាផ្លែដូងធ្លាក់ក្បែរជើង ហើយលោត ព្រោះភ្ញាក់ពេក(ដូចជាក្នុងរូបខាងក្រោម) ឬក៏លើកដៃឡើងធ្វើជាដើមដូងដែលត្រូវខ្យល់បក់បោករេចុះរេឡើង។